# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | ភាគីទាំងអស់ |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 30-Apr-2014, 15:40
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) នៅក្នុងសំណុំរឿង០០២/០២

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

មេធាវីការពារក្តីជនជាប់ចោទ
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Arthur VERCKEN
Anta GUISSE

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
ពេជ អង្គ
Elisabeth SIMONNEAU FORT

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**ចម្លងជូន:**

ជនជាប់ចោទ
នួន ជា
ខៀវ សំផន

## I. សេចក្តីផ្តើម

១- មេធាវីការពារក្តី នួន ជា មេធាវីការពារក្តី ខៀវ សំផន សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា (“ភាគី”) សូមស្វែងរកការបំភ្លឺពីអង្គជំនុំជម្រះសាលាដំបូង អំពីការអនុវត្តវិធាន៨៧(៤) នៅក្នុងបរិបទនៃសវនាការខាងមុខនៅក្នុងសំណុំរឿង០០២/០២[1]។

២- វិធាន៨៧(៤) ចែងថា ក្នុងកំឡុងពេលសវនាការ អង្គជំនុំជម្រះអាចស្តាប់ចម្លើយបុគ្គលណាម្នាក់ ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ វិធាននេះក៏បានចែងបន្ថែមថា ភាគីដែលស្នើសុំតាមវិធាននេះ “ត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេល*<u>ការចាប់ផ្តើមជំនុំជម្រះ</u>*”[2]។ ភាគីមានទស្សនៈរួមថា តាមកាលៈទេសៈបច្ចុប្បន្ន ឃ្លាថា “នៅមុនពេលការចាប់ផ្តើមជំនុំជម្រះ” សំដៅលើការចាប់ផ្តើមជំនុំជម្រះនាពេលបន្ទាប់ មានន័យថា ការជំនុំជម្រះក្នុងសំណុំរឿង០០២/០២។ ភាគីសូមស្នើអង្គជំនុំជម្រះបញ្ជាក់លើការយល់ឃើញនេះ។

៣- ភាគីសន្និដ្ឋានថា ការបកស្រាយខាងលើ គឺស៊ីសង្វាក់គ្នាទៅនឹងន័យត្រង់ និងស្មារតីនៃវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង។ ការបកស្រាយនេះធានាផងដែរថា ភាគីទាំងអស់អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងការរៀបចំ និងបង្ហាញភស្តុតាងពាក់ព័ន្ធ និងភរវនីយ នៅក្នុងសវនាការបន្ទាប់។

## II.ប្រវត្តិនីតិវិធី

៤- នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ ដោយបង្គាប់ឱ្យកម្រិតនូវបទចោទ និងការចោទប្រកាន់នានា ដែលត្រូវស្តាប់នៅ

---

[1] សំណើនេះត្រូវបានព្រាងជាភាសាអង់គ្លេស ហើយមិនមានពេលគ្រប់គ្រាន់សម្រាប់បកប្រែភាសាបារាំងមុនពេលដាក់ ដោយសារបញ្ហានេះមានភាពបន្ទាន់។ ការមិនមានការបកប្រែជាភាសាបារាំងចុងក្រោយមានផលប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ក្នុងការយល់ដឹងឱ្យបានពេញលេញនូវអំណះអំណាងផ្លូវច្បាប់ក្នុងសំណើនេះ។ ទោះបីយ៉ាងណាក៏ដោយ ភាពចាំបាច់សម្រាប់ការបញ្ជាក់នេះ គឺត្រូវតែយល់ដឹងឱ្យបានពេញលេញ និងគាំទ្រដោយមេធាវីការពារក្តី ខៀវ សំផន។

[2] សង្កត់ន័យត្រង់អក្សរទ្រេតដែលមានគូសបន្ទាត់ពីក្រោម។

ក្នុងការជំនុំជម្រះលើកទីមួយដែលបានកំណត់ថា សំណុំរឿង០០២/០១[3]។ ដោយមានការបង្គាប់ពីអង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងក៏បានត្រៀមរៀបចំគម្រោងសង្ខេបសម្រាប់ការដឹកនាំសវនាការក្នុងពេលអនាគត[4]។ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញ "សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២" ដែលក្នុងសេចក្ដីសម្រេចនេះបានបំបែកកិច្ចដំណើរការនីតិវិធីដែលនៅសេសសល់ក្នុងសំណុំរឿង០០២ និងបានជ្រើសរើសបទចោទ ទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ព្រហ្មទណ្ឌមួយចំនួន ទៅបញ្ចូលក្នុងសវនាការបន្ទាប់ គឺសំណុំរឿង០០២/០២[5]។

៥- នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានចេញ "ដីកាបង្គាប់ឱ្យដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីត្រៀមរៀបចំសវនាការក្នុងសំណុំរឿង០០២/០២" ("ដីកាបង្គាប់ឱ្យត្រៀមរៀបចំសវនាការ")[6]។ នៅក្នុងដីកាបង្គាប់ឱ្យត្រៀមរៀបចំសវនាការនេះ អង្គជំនុំជម្រះបានបង្គាប់ឱ្យភាគីដាក់បញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានធ្វើបច្ចុប្បន្នភាព ព្រមទាំងបញ្ជីឯកសារ និងវត្ថុតាងបច្ចុប្បន្នភាពនានាផងដែរ។ អង្គជំនុំជម្រះបានបញ្ជាក់ថា សំណើសុំស្ដាប់សាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីថ្មី ព្រមទាំងសំណើសុំដាក់ភ័ស្ដុតាង ឬវត្ថុតាងថ្មីបន្ថែមទៀត គួរតែដាក់ស្របតាមវិធាន៨៧(៤)[7]។

## III. សេចក្ដីសន្និដ្ឋាន និងសំណើសុំការបំភ្លឺ

៦- ភាគីបានដឹកនាំកិច្ចប្រជុំនានា ដើម្បីជួយសម្រួលដល់ការរៀបចំឱ្យមានរបៀបរៀបរយ សម្រាប់ការជំនុំជម្រះ និងដើម្បីចាត់ដំណើរការ បើសិនជាអាច ដោយឈរលើមូលដ្ឋាននៃការមូលមតិគ្នាលើបញ្ហារដ្ឋបាល និងការធ្វើផែនការ។ សេចក្ដីសន្និដ្ឋានដែលបានលើកឡើងក្នុងសំណើសុំនេះ ឆ្លុះបញ្ចាំងពីទស្សនៈរួមរបស់ភាគី នៅក្នុងការអនុវត្តវិធាន៨៧(៤)។

[3] **E284** សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, ត្រង់កថាខណ្ឌ៨៩-៩០។

[4] ដដែលដូចខាងលើ, ត្រង់កថាខណ្ឌ១៥២-១៥៣; ឧបសម្ព័ន្ធ។

[5] **E301/9/1** សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២, ៤ មេសា ២០១៤។

[6] **E305** ដីកាបង្គាប់ឱ្យដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង០០២/០២, ៨ មេសា ២០១៤។

[7] ដដែលដូចខាងលើ, ត្រង់កថាខណ្ឌ១ និង១៤។

៧- ដូចបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានបំបែកសំណុំរឿង០០២ជា*សវនាការច្រើនវគ្គ*[8]។ វគ្គដំបូងក្នុងចំណោមវគ្គទាំងនេះគឺ សំណុំរឿង០០២/០១ បានបញ្ចប់កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣[9]។ ភាគីនានា និងអង្គជំនុំជម្រះ ឥឡូវនេះកំពុងត្រៀមរៀបចំចាប់ផ្ដើមធ្វើសវនាការលើសំណុំរឿង០០២/០២។ វិធាន៨០*ស្ទួន* នៃវិធានផ្ទៃក្នុង បានចែងថា "សវនាការមួយ ចាប់ ផ្ដើម ដោយសវនាការបឋម"។ ដូច្នេះ *សវនាការ*នីមួយៗត្រូវតែចាប់ផ្ដើមឡើងដោយសវនាការបឋម។ *នោះជាសវនាការដែល*អង្គជំនុំជម្រះត្រូវពិចារណាលើបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញសក្ខីភាពរបស់ភាគីនានា[10]។ ភាសាត្រង់ៗ និងច្បាស់ៗ នៃវិធាន៨៧.៤ នៃវិធានផ្ទៃក្នុង បង្គាប់ឱ្យមានការកម្រិតលើការដាក់ភស្តុតាងថ្មីៗបញ្ចូលនៅពេលនោះ ឱ្យទាន់ពេលវេលា គឺនៅ*ពេលចាប់ផ្ដើម* នៃ*វគ្គសវនាការ* នីមួយៗ។ ដូច្នេះ ករណីបច្ចុប្បន្នមួយនេះ វិធាន៨៧.៤នៃវិធានផ្ទៃក្នុង បានយោងពីកាលបរិច្ឆេទនៃសវនាការបឋមលើសំណុំរឿង០០២/០២ ដែលមិនទាន់បានធ្វើនៅឡើយ។

៨- ជម្រើសបកស្រាយម្យ៉ាងទៀត - ឧទាហរណ៍ថា វិធាន៨៧.៤ ត្រូវអនុវត្តដោយមានការយោងត្រឡប់ទៅរកសវនាការបឋមដែលបានធ្វើកាលពីខែមិថុនា ឆ្នាំ២០១១ - នោះគឺពុំមានលក្ខណៈជាការអនុវត្ត និងពុំសមហេតុសមផលទេ។ គេតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្ដីសម្រេចជាច្រើនទាក់ទងនឹង ថាតើឯកសារ ឬសាក្សីនីមួយៗ សមស្របទៅតាមលក្ខខណ្ឌតម្រូវនៃវិធាន៨៧.៤ ហើយឬនៅ ដោយសារថាវាមិនមាននៅក្នុងបញ្ជីនានារបស់ភាគី ដែលបានដាក់កាលពី ឆ្នាំ២០១១ នោះឡើយ។ វាក៏

---

[8] ជាឧទាហរណ៍, សូមអាន **E284** សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, ត្រង់កថាខណ្ឌទី៩៥,៩៨,៩៩,១៥០-១៥៣។ **E301/9/1** សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២, ៤ មេសា ២០១៤, ត្រង់កថាខណ្ឌទី១៩ ដោយបានយោងទៅ "សវនាការពីរដាច់ពីគ្នា" ដែលជាការផ្ទុយទៅនឹង "សវនាការមួយដែលមិនបំបែក"។ សូមអានផងដែរ កថាខណ្ឌទី២២,២៣ (ការយោងទៅដល់ "ការបំបែកសវនាការច្រើន" និងកថាខណ្ឌទី២៤ ("សវនាការមួយ ឬច្រើន បន្តបន្ទាប់")។ បញ្ហានេះក៏ជាការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូលស្ដីពីផលប៉ះពាល់នៃការបំបែកកិច្ចដំណើរការនីតិវិធីផងដែរ។ សូមអាន **E284/4/8** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២, ២៥ វិច្ឆិកា ២០១៣, ត្រង់កថាខណ្ឌទី៣៧ (ដោយបានយោងទៅដល់ភាពខុសគ្នារវាង "សវនាការតែមួយលើគ្រប់បទចោទទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយ [និង]… ធ្វើសវនាការច្រើន"), កថាខណ្ឌទី៣៨-៣៩, ៤៣។

[9] **E1/237.1** ប្រតិចារឹក, ត្រង់ ១៤:១៦:១២ ["អង្គជំនុំជម្រះសាលាដំបូង សូមប្រកាសបិទកិច្ចពិភាក្សាដេញដោល ពិនិត្យលើភស្តុតាងលើសំណុំរឿងក្ដី០០២/០១ ត្រឹមនេះ"] និងត្រង់ ១៤:១៨:៣៧ [ទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២/០២ … អង្គជំនុំជម្រះគ្រោងនឹងបើកកិច្ចប្រជុំរៀបចំសវនាការ … ដើម្បីពិនិត្យលើការរៀបចំការជំនុំជម្រះជាបន្តទៀតលើសំណុំរឿងលេខ០០២/០២"]។

[10] វិធាន៨០.១ និង ៨០.២ នៃវិធានផ្ទៃក្នុង។:

អាចមានន័យផងដែរថា ភាគីនានា*មិនធ្លាប់ពេញចិត្ត*នឹងវិធាន៨៧.៤ឡើយ កាលណាពួកគេមានបំណង ពិនិត្យឡើងវិញនូវបញ្ជីនានារបស់ពួកគេដែលស្របតាមវិធាន៨០ កាលពីឆ្នាំ២០១១ ដើម្បីផាត់ចេញនូវសាក្សីទាំងឡាយណាដែលគេពិចារណាទៅឃើញថាលែងមានសារៈសំខាន់ទៀតហើយ ហើយដាក់បញ្ចូលវិញនូវសាក្សី (ឬឯកសារ) ទាំងឡាយណាដែលជាលក្ខណៈបច្ចេកទេស "អាចរកបាន" នៅក្នុងឆ្នាំ២០១១ ប៉ុន្តែកាលនោះគេមិនបានជ្រើសរើសយកទេ។ បញ្ហានេះអាចបណ្តាលឲ្យមានការកម្រិតមួយដែលមិនយុត្តិធម៌ ដែលវិធាន៨៧.៤ មិនដែលបានគ្រោងទុកជាមុនដូច្នោះទេ។ វាក៏អាចរំលោភផងដែរទៅនឹងនិយមន័យ ត្រង់ៗនៃវិធាន៨៧.៤ ដោយការអនុវត្តវាទៅក្នុងសំណុំរឿងទាំងមូល (ដោយមិនគិតពីការបំបែកឲ្យទៅជាសវនាការជាច្រើនវគ្គ) ខណៈដែលវិធានអនុវត្តយ៉ាងច្បាស់លាស់ទៅលើ*វគ្គសវនាការ*[11]។

៩- ការអនុវត្តវិធាន៨៧.៤ ដាច់ដោយឡែកពីគ្នា ទៅលើសវនាការនីមួយៗ គឺសមស្របទៅនឹងសិទ្ធិរបស់ជនជាប់ចោទ ក្នុងមាត្រា៣៣*ថ្មី*[12], គោលការណ៍ជាសារវ័ន្តដែលមានចែងនៅក្នុងមាត្រា២១ នៃវិធានផ្ទៃក្នុង[13], ក៏ដូចជាគោលបំណងសំខាន់នានានៃសវនាការនេះផងដែរ គឺដើម្បីបញ្ជាក់ពីការពិតនៃការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ[14]។ វាជាផលប្រយោជន៍នៃសវនាការមួយដ៏ត្រឹមត្រូវ និងការបញ្ជាក់ពីការពិត ដើម្បីអនុញ្ញាតឲ្យភាគីនានាបានធ្វើការវាយតម្លៃថ្មីមួយ ដោយសុទ្ធចិត្តទៅលើភស្តុតាងបន្ថែម (ក្រៅពីអ្វីដែលបានស្តាប់ និងបានទទួលយករួចហើយ នៅក្នុងសំណុំរឿង០០២/០១) ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២។

១០- បន្ទាប់ពីសវនាការពីរឆ្នាំ ការវាយតម្លៃរបស់ភាគីនានាទៅលើអ្វីដែលភស្តុតាងអាចនឹងនាំមកនូវការបញ្ជាក់ខ្ពស់បំផុតពីការពិតនៃការចោទប្រកាន់ និងទីកន្លែងឧក្រិដ្ឋកម្មទាំងឡាយដែលនៅសេសសល់

---

[11] វាក៏បានលើកទឹកចិត្តដល់ភាគីនានាផងដែរ ឲ្យដាក់បញ្ជីឈ្មោះសាក្សី និងបញ្ជីឯកសារ ជាច្រើនលើសលប់ នៅពេលចាប់ផ្តើមលើសំណុំរឿងនីមួយៗ ដោយបានដាក់ទៅក្នុងបញ្ជីនូវបុគ្គល និងឯកសារនីមួយៗដែលខ្លួនបានដឹង ដែលអាចនឹងយល់បានថាវាមានការទាក់ទងគ្នា។

[12] បទប្បញ្ញត្តិនេះតម្រូវឲ្យត្រូវទៅតាមមាត្រា១៤ នៃ*កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ*, ដែលវាបានផ្តល់ដល់ជនជាប់ចោទនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (១៤.១) ក៏ដូចជាសិទ្ធិក្នុងការ "មានពេលវេលា ព្រមទាំងសម្ភារៈគ្រប់គ្រាន់ ក្នុងការការពារខ្លួន" (១៤.៣.ខ), សិទ្ធិក្នុងការ "ការពារខ្លួនដោយខ្លួនឯង" (១៤.៣.ឃ), និងសិទ្ធិក្នុងការ "បានចូលរួមពិនិត្យ និងសាកសួរដេញដោលទៅលើសាក្សីខាងឆ្លើយការពារខ្លួន ដោយស្ថិតនៅក្រោមលក្ខខណ្ឌច្បាប់ស្មើគ្នា នឹងសាក្សីខាងគូបដិបក្ខ" (១៤.៣.ង) ផងដែរ។

[13] វិធាន២១.១.ក នៃវិធានផ្ទៃក្នុង៖ "ដំណើរការនីតិវិធីនៅក្នុង អវតក ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

[14] វិធាន៨៥.១, ៨៧.១, ៨៧.៣ និង ៨៧.៤ នៃវិធានផ្ទៃក្នុង។

ដែលចាំបាច់ឱ្យមានការវិវដ្ត។ វាជាការប្រាកដណាស់ដែលថាពេលនេះ យុទ្ធសាស្ត្រនានាត្រូវបានគេផ្តោតយកចិត្តទុកដាក់ច្រើនជាងមុន។ ការរារាំងភាគីនានាមិនឱ្យដាក់ជូននូវភស្តុតាងជាភវនីយភាពដែល *ជាបច្ចេកទេស* អាចរកបានក្នុងឆ្នាំ២០១១ ក៏ប៉ុន្តែ*កាលនោះ* គេបានយល់ឃើញថាវាមិនសំខាន់ (ឬ ដោយគ្រាន់តែភាគីនានាមិនបានដឹង) គឺមិនបានបម្រើជាប្រយោជន៍ឱ្យដល់គោលបំណងទេ។ ផ្ទុយទៅវិញ អាចរារាំងដល់អង្គជំនុំជម្រះមិនឱ្យបានពិចារណាលើភស្តុតាង*ទាំងអស់* ដែលបច្ចុប្បន្ននេះ ត្រូវបានភាគីនានាកំណត់អត្តសញ្ញាណថាមានតម្លៃជាភវនីយភាពខ្ពស់ និងនាំមកនូវការបញ្ជាក់ពីការពិត។ គេក៏ត្រូវគិតផងដែរថា ចាប់តាំងពីសវនាការបឋមនៅក្នុងសំណុំរឿង០០២/០១មក គឺមានការផ្លាស់ប្តូរទាំងនៅក្នុងក្រុមមេធាវីការពារក្តី និងទាំងនៅក្នុងក្រុមដើមបណ្តឹងរដ្ឋប្បវេណី។ វាមិនមែនជាផលប្រយោជន៍នៃយុត្តិធម៌ទេ ក្នុងការដែលបានចងភ្ជាប់ទៅនឹងបញ្ជីនានារបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី ហើយឯកសារទាំងឡាយដែលបុព្វាធិការីបានត្រៀមរៀបចំ នៅក្នុងបរិបទនៃការត្រៀមរៀបចំសម្រាប់សវនាការបន្ទាប់នេះ។

១១- លើសពីនេះ (កាលៈទេសៈបានផ្លាស់ប្តូរយ៉ាងសំខាន់ចាប់តាំងពីឆ្នាំ២០១១មក) សាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលត្រូវបានស្នើឱ្យផ្តល់សក្ខីកម្មអាចទទួលមរណភាព ឬម្យ៉ាងទៀតមិនអាចផ្តល់សក្ខីកម្មកើត។ ភស្តុតាងបន្ថែមមានមួយចំនួនបានលេចឡើង មិនអាចរកបាននៅក្នុងឆ្នាំ២០១១ មួយចំនួនបានមកពីការធ្វើសម្ភាសន៍ដែលកំពុងតែបន្តធ្វើដោយបណ្តាអង្គការពីខាងក្រៅនានាដូចជា៖ មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam), មួយចំនួនបានមកពីការស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០៣ និង០០៤ ដែលមានជាន់គ្នានៅក្នុងផ្នែកខ្លះជាមួយនឹងសំណុំរឿងលេខ០០២/០២។ នៅក្នុងខណៈដែលការផ្លាស់ប្តូរកាលៈទេសៈទាំងនេះទំនងជាបំពេញគ្រប់ទៅតាមលក្ខខណ្ឌតម្រូវនានានៅក្នុងវិធាន៨៧(៤)ដែលតម្រូវឱ្យភាគីនានាដាក់សារណា ស្តីពីឯកសារដ៏មានសក្តានុពលចំនួនរាប់រយ និងសាក្សីរាប់សិបនាក់ និងការដាក់បន្ទុកលើអង្គជំនុំជម្រះសាលាដំបូងឱ្យសម្រេចលើពាក្យសុំដែលមានចំនួនដ៏ច្រើន អាចធ្វើឱ្យការជឿនលឿននៃកិច្ចដំណើរការរឿងក្តី មានភាពយឺតយ៉ាវដោយមិនមានការចាំបាច់ ដោយពុំមានអត្ថប្រយោជន៍ដល់ភាគីណាមួយ ឬដល់អង្គជំនុំជម្រះនោះឡើយ។ ការអនុម័តយកនូវការបកស្រាយទាំងឡាយដែលស្នើឡើងដោយភាគីនានាដូចនៅក្នុសំណើនេះ អាចជួយសន្សំសំចៃនូវធនធានបានមួយផ្នែកដ៏ធំ ដែលបើពុំនោះទេ អង្គជំនុំជម្រះមុខជានឹងត្រូវបូជាទៅលើការសម្រេចលើពាក្យសុំដាច់ដោយឡែកៗពីគ្នាទាក់ទងនឹងសាក្សី និងភស្តុតាងដែលបានស្នើសុំថ្មីៗទៀត។

១២- ហេតុដូចនេះ នៅក្នុងពេលដែលភាគីនានាកំពុងតែយល់ឃើញដោយមុតមាំថា ការបកស្រាយដែលនៅក្នុងកថាខណ្ឌ៧ខាងលើ ផ្ទុះបញ្ចាំងឱ្យឃើញពីអត្ថន័យជាក់ស្តែងនៃវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងនោះ វិធីសាស្ត្រដែលបានស្នើនៅក្នុងសំណើនេះ ក៏ជួយបង្កលក្ខណៈងាយស្រួលដល់ការដឹកនាំនៃកិច្ចដំណើរការនីតិវិធីបានឆាប់រហ័សដែរ។ ក្នុងកាលៈទេសៈមួយចំនួននៅក្នុងអម្លុងពេលនៃការជំនុំជម្រះលើសំណុំរឿងលេខ០០២/០១ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យទទួលយកនូវភស្តុតាងដែលមិនមែនស្នើឡើងដោយភាគីនានានៅមុនការចាប់ផ្តើមនៃការជំនុំជម្រះលើសំណុំរឿងលេខ០០២/០១។ ឧទាហរណ៍ដូចជា អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចដូចនេះ នៅក្នុងករណីបើសិនជារកឃើញថា ឯកសារដែលស្នើឡើងថ្មីមានការជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធទៅនឹងភស្តុតាងផ្សេងៗទៀត ដែលត្រូវបានកំណត់អត្តសញ្ញាណរួចហើយនៅក្នុងបញ្ជីរបស់ភាគី និងនៅក្នុងករណីផលប្រយោជន៍ដល់យុត្តិធម៌ដែលអនុញ្ញាតឱ្យប្រភពទាំងពីរត្រូវបានធ្វើការវាយតម្លៃរួមជាមួយគ្នា[15]។ ក៏ទទួលយកភស្តុតាងដូចនេះផងដែរ នៅក្នុងករណីប្រសិនជាអង្គជំនុំជម្រះយល់ឃើញថាចាំបាច់ត្រូវការពារដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដ៏ត្រឹមត្រូវ[16]។

១៣- ដើម្បីជៀសវាងនូវការមន្ទិលសង្ស័យ គ្រប់ភាគីទាំងអស់បានទទួលយល់ព្រមគ្នាថា ភស្តុតាងណាមួយដែលអង្គជំនុំជម្រះមិនទាន់បានទទួលយកនៅឡើយ ត្រូវតែបំពេញឱ្យបានទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ការទទួលយក ដូចដែលមានចែងនៅក្នុងវិធាន៨៧(៣)។ ក៏ប៉ុន្តែ នៅមុនពេលធ្វើសវនាការបឋមនៃសំណុំរឿងលេខ០០២/០២ មិនត្រូវយកវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង មកប្រើចំពោះភស្តុតាងដែលភាគីនានាបានដាក់ជូនដោយអនុលោមតាមវិធាន៨០ ស្របតាមការណែនាំរបស់អង្គជំនុំជម្រះនោះឡើយ។

១៤- អាស្រ័យហេតុនេះ គ្រប់ភាគីទាំងអស់សូមស្នើដោយគោរពដល់អង្គជំនុំជម្រះ សូមមេត្តាបញ្ជាក់ថា៖

---

[15] ឯកសារលេខ **E172/24/5/1** ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើលើកទីពីរ ស្តីពីវិធាន៨៧(៤) ទាក់ទងអំពីឯកសារដែលអាចត្រូវបានប្រើប្រាស់ នៅក្នុងអម្លុងពេលធ្វើការសួរដេញដោលអ្នកជំនាញ លោក David Chandler (ឯកសារលេខ E172/24/5), ចុះថ្ងៃទី១៦ កក្កដា ២០១២, កថាខណ្ឌទី៣។ ឯកសារលេខ **E299** សេចក្តីសម្រេចលើសេចក្តីជំទាស់ស្តីពីភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារិកនៅសំណុំរឿងលេខ០០១ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី១៥ សីហា ២០១៣, ត្រង់កថាខណ្ឌទី៣៥ -៣៦។

[16] ឯកសារលេខ **E190** សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត, ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២, ត្រង់កថាខណ្ឌទី៣៦-៣៧, សូមមេត្តាអាន កថាខណ្ឌទី២១។

(ក) ការជំនុំជម្រះនៅក្នុងសំណុំរឿងលេខ០០២/០២ នឹងចាប់ផ្ដើមធ្វើដោយការបើកសវនាការបឋម ដែលនឹងកំណត់កាលបរិច្ឆេទជូន។ និង

(ខ) នៅក្នុងសំណុំរឿងលេខ០០២/០២ វិធាន៨៧(៤)នៃវិធានផ្ទៃក្នុងនឹងត្រូវបានយកមកអនុវត្តតែចំពោះភស្តុតាងដែលស្នើឡើងថ្មីៗដោយភាគីណាមួយ បន្ទាប់ពីការបើកសវនាការជំនុំជម្រះក្ដី គឺថានៅក្រោយពេលសវនាការបឋមនាពេលខាងមុខនេះតែប៉ុណ្ណោះ៕

សូមដាក់ជូនដោយសេចក្ដីគោរព។

| ឈ្មោះ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|
| លោកស្រី ជា លាង,<br>សហព្រះរាជអាជ្ញា | [signature] | ថ្ងៃទី៣០ ខែមេសា<br>ឆ្នាំ២០១៤ |
| លោក Nicholas KOUMJIAN,<br>សហព្រះរាជអាជ្ញា | [signature] | ថ្ងៃទី៣០ ខែមេសា<br>ឆ្នាំ២០១៤ |
| លោក សុន អារុណ,<br>សហមេធាវីរបស់ នួន ជា | FOR [signature] | ថ្ងៃទី៣០ ខែមេសា<br>ឆ្នាំ២០១៤ |
| លោក Victor KOPPE,<br>សហមេធាវីរបស់ នួន ជា | [signature] | ថ្ងៃទី៣០ ខែមេសា<br>ឆ្នាំ២០១៤ |
| លោក គង់ សំអុន,<br>សហមេធាវីរបស់ ខៀវ សំផន | [signature] | ថ្ងៃទី៣០ ខែមេសា<br>ឆ្នាំ២០១៤ |
| លោក Arthur VERKEN,<br>សហមេធាវីរបស់ ខៀវ សំផន | For [signature] | ថ្ងៃទី៣០ ខែមេសា<br>ឆ្នាំ២០១៤ |
| លោកស្រី Anta GUISSE,<br>សហមេធាវីរបស់ ខៀវ សំផន | For [signature] | ថ្ងៃទី៣០ ខែមេសា<br>ឆ្នាំ២០១៤ |
| លោក ពេជ្រ អង្គ,<br>សហមេធាវីនាំមុខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី | [signature] | ថ្ងៃទី៣០ ខែមេសា<br>ឆ្នាំ២០១៤ |

| | | |
|---|---|---|
| លោក Elizabeth SIMONEAU FORT,<br>សហមេធាវីនាំមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណី | | ថ្ងៃទី៣០ ខែមេសា<br>ឆ្នាំ២០១៤ |